**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៧ ៦៩៦នាក់ នៃរោងចក្រទាំង១៥ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង១៥ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ១២កើត ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០២៣

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣
### បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ
### ចំនួន ១៥ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 15 |
| 1 | ក្រុមហ៊ុន ផាភីលៀន ថេកស្តាយ (ខេមបូឌា)ខូអិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ខេមហ្វអេវើ | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ហ៊ូ លូ ហ្គាមេន | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ស៊ីន ឡាន (ខេមបូឌា)ហ្គាមេន ខមភេនីលីមីធីត | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ឈុនឌឹង ព្រីនធីង ខូអិលធីឌី | ភ្នំពេញ |
| 6 | ក្រុមហ៊ុន អេចខេ ប៊ុលតិច មេនូហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ស្តារឡៃថ៍ អឹភែរឹល មេនូហ្វេកឆឺរីង | កណ្តាល |
| 8 | ក្រុមហ៊ុន បាវហ្សាន់ អ៊ិនដាសស្ទ្រៀល | កណ្តាល |
| 9 | ក្រុមហ៊ុន វីង ស្តារ ស៊ូ | កំពង់ស្ពឺ |
| 10 | ក្រុមហ៊ុន វីនគ្រោន (ខេមបូឌា) អិនដាសស្ទ្រៀល ឯ ក | កំពង់ស្ពឺ |
| 11 | ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី | កំពង់ចាម |
| 13 | ក្រុមហ៊ុន ស៊ុន ស៊ីនឡាក់ហ្គេដអ៊ីនដាសស្ទ្រី(ខេមបូឌា) | កំពង់ឆ្នាំង |
| 14 | ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ | កំពង់ឆ្នាំង |
| 15 | ក្រុមហ៊ុន អៅដរ ហ្គៀ (ខេមបូឌា) ឯ.ក | តាកែវ |